## ប្រភពឯកសារ

ការិយាល័យឥណទាន

លោកអ្នកមានសិទ្ធិទទួលបាន សំណៅឯកសាររបាយការណ៍ឥណទានមួយច្បាប់ដោយឥតគិតថ្លៃ បើលោកអ្នកបានក្លាយជាជនរងគ្រោះនៃការលួចអត្តសញ្ញាណ បានរងការបដិសេធ ចំពោះការផ្តល់ឥណទាន ទទួលបានអត្ថប្រយោជន៍សុខមាលភាព ឬគ្មានការងារធ្វើ ។ សូម ទាក់ទងទីភ្នាក់ងារឥណទានមួយ ក្នុងចំណោមទីភ្នាក់ងារ ខាងក្រោមនេះ ឬចូលមើលគេហទំព័រ www.annualcreditreport.com

Equifax ww.equifax.com

P.O. Box 740241, Atlanta, Georgia 30374-0241

- ដើម្បីបញ្ជាឱ្យចេញរបាយការណ៍ឥណទានរបស់លោកអ្នក សូមទូរសព្ទទៅលេខ (800) 685-1111
- ដើម្បីរាយការណ៍ អំពីការក្លែងបន្លំ សូមទូរសព្ទទៅលេខ (800) 525-6285

Experian (អតីត TRW) www.experian.com

P.O. Box 949, Atlanta, Georgia 75013-0949

- ដើម្បីបញ្ជាឱ្យចេញរបាយការណ៍ឥណទាន របស់លោកអ្នក សូមទូរសព្ទទៅលេខ (888) 397-3742
- ដើម្បីរាយការណ៍ អំពីការក្លែងបន្លំ សូមទូរសព្ទទៅលេខ (888) 397-3742

Trans Union www.transunion.com

P.O. Box 390, Springfield, Pennsylvania 19064-0390

- ដើម្បីបញ្ជាឱ្យចេញរបាយការណ៍ឥណទាន របស់លោកអ្នក សូមទូរសព្ទទៅលេខ (800) 916-8800
- ដើម្បីរាយការណ៍ អំពីការក្លែងបន្លំ សូមទូរសព្ទទៅលេខ (800) 680-7289

ទីភ្នាក់ងារសហព័ន្ធ

គណកម្មការពាណិជ្ជកម្មសហព័ន្ធ www.ftc.gov

600 Pennsylvania Ave, NW, Washington, DC 20580

- ដើម្បីរាយការណ៍ អំពីការក្លែងបន្លំ សូមទូរសព្ទទៅលេខ (877) 438-4338

រដ្ឋបាលសន្តិសុខសង្គម www.ssa.gov

- ដើម្បីរាយការណ៍ អំពីការក្លែងបន្លំ សូមទូរសព្ទទៅលេខ (800) 269-0271

សេវាប្រៃសណីយ៍ ស.រ.អ ww.usps.gov

- សូមរាយការណ៍ អំពីការលួចតាមសំបុត្រ ទៅកាន់អ្នកត្រួតពិនិត្យប្រៃសណីយ៍

លេខករណី របស់ក្រសួងនគរបាល ទីក្រុងឡុងប៊ិច របស់លោកអ្នកគឺ :________________________

សូមកត់ត្រាលេខករណីនេះទុក នៅក្នុងសីមីកំណត់ហេតុលម្អិតរបស់លោកអ្នក និងប្រើវា នៅពេលដែលលោកអ្នកទំនាក់ទំនងជាមួយ ក្រុមហ៊ុន ឬទីភ្នាក់ងារអនុវត្តច្បាប់ ដែលពាក់ព័ន្ធនឹងរបាយការណ៍នេះ ។ អាស្រ័យតាមទីកន្លែង (ដែនសមត្ថកិច្ច) ដែលបទល្មើសបានកើតមានឡើង (មុខទំនិញ ឬប្រភេទសេវា ដែលទទួលបាន ឬបានប្រគល់ឱ្យ) អ្នកស៊ើបអង្កេតម្នាក់របស់ LBPD អាច ឬមិនអាច ត្រូវបានកំណត់ ចំពោះករណីនេះ ។ ករណីនេះអាចត្រូវផ្ទេរទៅ ទីភ្នាក់ងារអនុវត្តច្បាប់មួយទៀត បើបទល្មើសបានកើតមានឡើង នៅក្នុងដែនសមត្ថកិច្ចមួយផ្សេងទៀត ។

កំណត់សម្គាល់ :

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

ក្រសួងនគរបាល ទីក្រុងឡុងប៊ិច
ព័ត៌មានលម្អិត អំពីការលួចអត្តសញ្ញាណ
400 West Broadway Avenue Long Beach,
CA 90802

ដើម្បីដាក់របាយការណ៍ សូមទូរសព្ទទៅ :

ស្ថានីយធំ : (562) 570-7312

បណ្តាញទូរសព្ទទីមួយ នៃផ្នែកព័ត៌មានលម្អិតអំពីការលួចអត្តសញ្ញាណ : (562) 570-7602

www.longbeach.gov/police/




# ការលួចអត្តសញ្ញាណ

ការលួចអត្តសញ្ញាណ គឺជាបទឧក្រិដ្ឋ ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស នៅសហរដ្ឋអាមេរិក ។ ការខាតបង់ពាក់ព័ន្ធនឹងការលួចអត្តសញ្ញាណ មានទំហំសរុប ជាទឹកប្រាក់ ចំនួន 50 ពាន់លានដុល្លារ នៅឆ្នាំ 2005 ។ ការលួចអត្តសញ្ញាណមានពាក់ព័ន្ធនឹង ការទទួលបានចំណែកសំខាន់ៗ នៃព័ត៌មានបញ្ជាក់អត្តសញ្ញាណរបស់មនុស្សម្នាក់ ដូចជា ឈ្មោះ, អាសយដ្ឋាន, ថ្ងៃខែឆ្នាំកំណើត, និងលេខប័ណ្ណសន្តិសុខសង្គមដើម្បីក្លែងខ្លួនធ្វើជាពួកគេ ។ បញ្ហានេះបើកលទ្ធភាពឱ្យចោរលួចអត្តសញ្ញាណ អាចប្រព្រឹត្តអំពើក្លែងបន្លំបាន ក្នុង រូបភាពជាច្រើន ។ គណកម្មការពាណិជ្ជកម្មសហព័ន្ធរបាយការណ៍ថា មនុស្សម្នាក់ក្នុងចំណោមប្រាំនាក់ នឹងក្លាយជាជនរងគ្រោះនៃការលួចអត្តសញ្ញាណ ។

ក្រសួងនគរបាល ទីក្រុងឡុងប៊ិច
អង្គភាពព័ត៌មានលម្អិតអំពីការលួចអត្តសញ្ញាណ 400 West Broadway Avenue
Long Beach, CA 90802

## គន្លឹះក្នុងការបង្ការ

សំបុត្រ

- ចាក់សោប្រអប់សំបុត្រ ហើយដកយកសំបុត្រចេញយ៉ាងរហ័ស ក្រោយមានការប្រគល់ឱ្យរួច ។
- ដាក់សំបុត្រផ្ញើរចេញ នៅក្នុងប្រអប់ប្រមូលសំបុត្រ នៃការិយាល័យប្រៃសណីយ៍ ឬនៅការិយាល័យប្រៃសណីយ៍តាមមូលដ្ឋានរបស់លោកអ្នក ។ កុំដាក់សំបុត្រនៅក្នុងប្រដាប់សម្រាប់ដាក់សំបុត្រ ដែលគ្មានសុវត្ថិភាព ។

ព័ត៌មានផ្ទាល់ខ្លួន

- កុំប្រាប់ព័ត៌មានផ្ទាល់ខ្លួន ដូចជា លេខប័ណ្ណសន្តិសុខសង្គម, ថ្ងៃខែឆ្នាំកំណើត, ឈ្មោះដើមរបស់ម្តាយ, លេខប័ណ្ណឥណទាន, ឬ PIN របស់ធនាគារលោកអ្នកតាមទូរសព្ទរបស់លោកអ្នក លើកលែងតែនៅពេល ដែលលោកអ្នក ជាអ្នកផ្តើមនិយាយទូរសព្ទចេញទៅ ។
- ទន្ទេញលេខប័ណ្ណសន្តិសុខសង្គម និងពាក្យសម្ងាត់ទាំងអស់របស់លោកអ្នកឱ្យចាំ ។ កុំកត់ត្រាវានៅលើប័ណ្ណណាមួយ ឬលើរបស់អ្វីមួយ ដែលមាននៅក្នុងកាបូបដាក់ហោប៉ៅរបស់លោកអ្នក ។
- ត្រូវយល់ដឹង អំពីការអន្ទងតាមសំបុត្រ ឬទូរសព្ទ ដែលបន្លំធ្វើជាការផ្សព្វផ្សាយ ដោយផ្តល់ជារង្វាន់ ភ្លាមៗ ឬរង្វាន់ដែលគេរៀបចំបង្កើតឡើង ដើម្បីទទួលបានព័ត៌មានបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់លោកអ្នក តែប៉ុណ្ណោះ ។
- ត្រូវប្រុងប្រយ័ត្ន នៅបង្ហើបប្រាប់ពី លេខគណនីចរន្ត, លេខប័ណ្ណឥណទាន, ឬទិន្នន័យហិរញ្ញវត្ថុផ្ទាល់ខ្លួន ផ្សេងទៀត នៅតាមអ៊ីនធឺណែត លើកលែងតែនៅពេល លោកអ្នកទទួលបានកូដបញ្ជាក់ភាពត្រឹមត្រូវ ដែលមានសុវត្ថិភាពពីក្រុមហ៊ុនផ្តល់សេវាដល់លោកអ្នក ។
- ត្រូវយល់ដឹង អំពីអ៊ីម៉ែលអន្ទង ឬសារជាអក្សរទាំងឡាយណាដែលស្នើសុំឱ្យលោកអ្នកចុចលើតំណមួយ ហើយធ្វើបច្ចុប្បន្នភាព ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ។ ក្រុមហ៊ុនស្របច្បាប់ នឹងមិនស្នើសុំឱ្យលោកអ្នក ធ្វើយ៉ាងដូច្នោះទេ ។

ប័ណ្ណឥណទាន និងរបាយការណ៍គណនី

- រាយការណ៍ ភ្លាមៗ អំពីរាល់ការបាត់បង់ ឬការលួចប័ណ្ណឥណទានទាំងអស់ ។
- ដកចេញឱ្យអស់ពីកាបូបហោប៉ៅរបស់លោកអ្នក នូវប័ណ្ណឥណទានជំនួយបន្ថែម ហើយលុបចោលប័ណ្ណដែលលោកអ្នកមិនប្រើ ។
- បញ្ជាឱ្យចេញរបាយការណ៍ប័ណ្ណឥណទាន របស់ លោកអ្នក ពីការិយាល័យឥណទានទាំងបី ក្នុងរយៈពេលមួយឆ្នាំ ម្តង ដើម្បីពិនិត្យមើលសកម្មភាពដែលលួចបន្លំ ។

## គន្លឹះក្នុងការបង្ការ

- កុំទុកបង្កាន់ដៃនៅឯម៉ាស៊ីនដកប្រាក់ធនាគារ, តាមបញ្ជរនៅធនាគារ, ប្រដាប់សម្រាប់ដាក់សម្រាម, ឬម៉ាស៊ីនបូមសាំង ។
- ចុះហត្ថលេខាភ្លាមៗ លើផ្នែកខាងក្រោយ របស់ប័ណ្ណឥណទានទាំងអស់ ។
- រក្សាទុករាល់បង្កាន់ដៃរបស់ប័ណ្ណឥណទាន ហើយ ផ្ទៀងផ្ទាត់វា ដោយធៀបនឹងវិក្កយបត្រប្រចាំខែរបស់លោកអ្នក ។
- ច្រៀកឯកសារសំណើឥណទាន ដែលមានមុនទទួល បានការឯកភាព, បង្កាន់ដៃប័ណ្ណឥណទាន, វិក្កយបត្រ, និងព័ត៌មានហិរញ្ញវត្ថុ ផ្សេងៗទៀត ឱ្យទៅជាបំណែកតូចៗ សិនមុនបោះវាចោល ។
- ត្រូវយល់ដឹង អំពីពេលវេលា ត្រូវរំពឹងថានឹងទទួលបានរបាយការណ៍ហិរញ្ញវត្ថុ ។ បើវាមិនមានផ្ញើរមកទេ ត្រូវទាក់ទងប្រាប់អ្នកផ្ញើ ។
- ជូនដំណឹងដល់ក្រុមហ៊ុន និងធនាគារដែលចេញប័ណ្ណឥណទាន នៅពេលដែលលោកអ្នក ផ្លាស់ប្តូរអាសយដ្ឋាន ឬលេខទូរសព្ទ ។
- កុំដាក់លេខប័ណ្ណឥណទាន ឬលេខគណនីហិរញ្ញវត្ថុផ្សេងទៀត នៅលើប័ណ្ណប្រៃសណីយ៍ ឬនៅក្រៅស្រោមសំបុត្រ ។
- បើលោកអ្នកកំពុងរំពឹងថានឹងទទួលបានប័ណ្ណឥណទានថ្មីមួយ ហើយវាមិនទាន់មកដល់ក្នុងលក្ខណៈដែលសមស្របនឹងពេលវេលា ទាក់ទងទៅធនាគារ ឬក្រុមហ៊ុនចេញប័ណ្ណឥណទានដែលពាក់ព័ន្ធ។

> បើលោកអ្នក ទទួលបានវិក្កយបត្រមួយ ពីម្ចាស់បំណុល ឬទីភ្នាក់ងារប្រមូលបំណុល ហើយលោកអ្នកមិនបានធ្វើការផ្លាស់ប្តូរទេនោះ លោកអ្នកអាចនឹងក្លាយទៅជាជនរងគ្រោះនៃការលួចអត្តសញ្ញាណហើយ ។ បន្ថែមលើការទាក់ទងទៅក្រសួងនគរបាល សូមផ្ញើសេចក្តីជូនដំណឹងលក្ខណៈគួរសម មួយច្បាប់ទៅ ទាំង ម្ចាស់បំណុល និងទីភ្នាក់ងារប្រមូលបំណុល ។

## ការរាយការណ៍ព័ត៌មាន

បើលោកអ្នកក្លាយជាជនរងគ្រោះ នៃការលួចអត្តសញ្ញាណ

- រៀបចំបង្កើតសឺមីមួយឡើង ដើម្បីរក្សាទុករាល់កំណត់ហេតុលម្អិត អំពីបទឧក្រិដ្ឋនេះ ។
- រក្សាទុកឯកសារកំណត់ហេតុ នៃរាល់បញ្ជីឈ្មោះទំនាក់ទំនងរបស់លោកអ្នក ហើយថតចម្លងទុក នូវរាល់ឯកសារទាំងអស់ ។
- ទាក់ទង ម្ចាស់បំណុលទាំងអស់ តាមទូរសព្ទ និងជាលាយលក្ខណ៍អក្សរ ដើម្បីផ្តល់ដំណឹងដល់ពួកគេ អំពីបញ្ហានេះ ។
- ទូរសព្ទទៅការិយាល័យណាមួយ នៃការិយាល័យឥណទានទាំងបី ដែលទទួលបន្ទុកដោះស្រាយការក្លែងបន្លំ ដើម្បីរាយការណ៍ប្រាប់ អំពីករណីនៃការលួច អត្តសញ្ញាណ ។ ស្នើសុំឱ្យមានផ្តល់របាយការណ៍ ស្តីពីដំណឹងអំពីការលួចបន្លំ/ផលប៉ះពាល់លើជនរងគ្រោះដែលមានដាក់ក្នុងឯកសារឥណទានរបស់លោកអ្នកដោយស្នើសុំឱ្យម្ចាស់បំណុលនានា ទូរសព្ទមកប្រាប់ លោកអ្នកសិន មុននឹងបើកគណនីថ្មីណាមួយ ។
- ស្នើសុំរបាយការណ៍ឥណទាន មួយច្បាប់ ។
- រាយការណ៍ អំពីបទឧក្រិដ្ឋ ទៅទីភ្នាក់ងារអនុវត្តច្បាប់តាមមូលដ្ឋានរបស់លោកអ្នក ក្នុងដែនសមត្ថកិច្ច នៃតំបន់ដែលលោកអ្នកនៅរស់នៅ ។ សូមផ្តល់ជូនពួកគេ នូវភស្តុតាងដែលលោកអ្នកបានចងក្រងរួច ឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ។
- បើលេខប័ណ្ណសន្តិសុខសង្គមរបស់លោកអ្នក កំពុងត្រូវបានគេប្រើប្រាស់ សូមទាក់ទងទៅ រដ្ឋបាលសន្តិសុខសង្គម តាមរយៈទូរសព្ទលេខ (800) 269-0271 ។
- សូមទាក់ទងទៅក្រសួងយានយន្ត (DMV) ដើម្បីពិនិត្យមើលថាតើ មានអាជ្ញាប័ណ្ណមួយទៀត ដែលគេបានចេញឱ្យដោយដាក់ឈ្មោះរបស់លោកអ្នកដែរ ឬយ៉ាងណា ។ បើដូច្នោះមែន ស្នើសុំលេខអាជ្ញាប័ណ្ណថ្មីមួយ ហើយបំពេញទម្រង់បែបបទបណ្តឹងរបស់ DMV ដើម្បីចាប់ផ្តើមដំណើរការស៊ើបអង្កេត លើករណីនៃការក្លែងបន្លំនេះ ។
- បើលោកអ្នកត្រូវបានកំណត់អត្តសញ្ញាណ ដោយខុសទាំងស្រុង ថាជាឧក្រិដ្ឋជន ក្រសួងយុត្តិធម៌នៃរដ្ឋកាលីហ្វ័រញ៉ាមានកន្លែងរក្សាទុកបញ្ជីក្លែងបន្លំអត្តសញ្ញាណ ។ រាយការណ៍អំពីបញ្ហានេះ ជូនទៅក្រសួងយុត្តិធម៌របស់រដ្ឋ តាមរយៈទូរសព្ទលេខ (888) 880-0240 (24 ម៉ោង/ថ្ងៃ) ឬ www.ag.ca.gov/idtheft/general.htm
- ប្រាប់ទៅធនាគារនានារបស់លោកអ្នក ឱ្យដាក់ទង់ចំណាំលើគណនីនានារបស់លោកអ្នក ហើយទាក់ទងមកលោកអ្នកដើម្បីបញ្ជាក់ប្រាប់ អំពីសកម្មភាពមិនប្រក្រតីណាមួយ ។ ស្នើសុំប្តូរ PIN និងពាក្យសម្ងាត់ថ្មី ។